# ការសំភាសន៍របស់អ៊ុំប្រុស ស្រ៊ឹម ស្រ៊ីន

កៈ អ្នកដែរសំភាសន៍ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ស្រ៊ឹម ស្រ៊ីន

## ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុសស្រ៊ឹម ស្រ៊ីន

អ៊ុំប្រុស ស្រ៊ឹម ស្រ៊ីន មានអាយុ62ឆ្នាំ នៅក្នុងឆ្នាំ2018។អ៊ុំប្រុស ស្រ៊ឹម ស្រ៊ីន មានភេទប្រុស។ អ៊ុំសប្រុស មានទីលំនៅបច្ចុប្បន្ននៅភូមិវាលខ្សាច់ ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ បាទមិនអីទេ

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ2 ឆ្នាំ2018 នៅភូមិ?

ខៈ ភូមិបាល្លាំងថ្មី

កៈ ភូមិបាល្លាំងថ្មី ឃុំអីគេដែរ?

ខៈ ភូមិវាលខ្សាច់ ឃុំរអាង

កៈ ភូមិវាលខ្សាច់ ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចឹងសំរាប់ឈ្មោះពេញរបស់អ៊ុំនឹងមាន ឈ្មោះអីគេដែរអ៊ុំ?

ខ៖ មានឈ្មោះ ស្រ៊ឹម ស្រ៊ីន

ក៖ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះកាលពីក្មេងនឹងមានធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងទេអ៊ុំ?

ខ៖ អត់មានទេនឹង

ក៖ ចឹងអត់មានទេហោសអ៊ុំ ចឹងសំរាប់អ៊ុំមានអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំអាយុ62ឆ្នាំ

ក៖ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ អត់បានចងចាំផងនឹង ខ្ញុំដឹងតែឆ្នាំ1956

ក៖ ចុះទីកន្លែងកំណើតរបស់អ៊ុំតើអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំកើតនៅភូមិវាលខ្សាច់នឹងតែម្តងនឹង

ក៖ ចឹងមានន័យថាអ៊ុំកើតនៅភូមិវាលខ្សាច់នឹងតែម្តងហោសអ៊ុំ?

ខ៖ បាទនៅនឹង

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំមានបងប្អូនចំនួន9នាក់

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនទី2

ក៖ ចុះមានស្រីប៉ុន្មាន ហើយប្រុសប៉ុន្មានដែរអ៊ុំ?

ខ៖ មានស្រី2នាក់ នឹងប្រុស7នាក់

ក៖ ចុះអ៊ុំអាចប្រាប់ឈ្មោះរបស់បងប្អូនរបស់អ៊ុំបានទេអ៊ុំ ប៉ុន្តែអ៊ុំនៅចងចាំឈ្មោះពួកគាត់ទាំងអស់ទេ?

ខ៖  បានតើនឹង

ក៖  ប៉ុន្តែពួកគាត់នៅរស់ទាំងអស់គ្នាតើហីអ៊ុំ?

ខ៖  នៅរស់ទាំងអស់នឹង អ្ហំ!មានស្លាប់មួយដែរ

ក៖  ប៉ុន្តែអ៊ុំអាចប្រាប់ឈ្មោះទាំងអស់បានដែរទេអ៊ុំ?

ខ៖  ប្រាប់បានតើនឹង

ក៖  ចុះឈ្មោះបងធំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  បងទី1ឈ្មោះស្រ៊ីម អ៊ែយ

ក៖  បន្ទាប់មកអ៊ុំ ចុះបន្ទាប់មកទៀតអ៊ុំ?

ខ៖  បន្ទាប់មកឈ្មោះស្រ៊ីម ស្រ៊ី ប៉ុន្មាននាក់ហើយទី3ហើយណា?

ក៖  បាទអ៊ុំទី3ហើយអ៊ុំ?

ខ៖  បន្ទាប់មកស្រ៊ីម គី

ក៖  នឹងទី4អ៊ុំ?

ខ៖  បន្ទាប់ឈ្មោះស្រ៊ីម ផ្លី

ក៖  បន្ទាប់ទី5អ៊ុំ?

ខ៖  បន្ទាប់មកឈ្មោះស្រ៊ីម តន

ក៖  បន្ទាប់មកទី6?

ខ៖  បន្ទាប់មកឈ្មោះស្រ៊ីម ធី

ក៖  បន្ទាប់មកទី7ឈ្មោះអីអ៊ុំ?

ខ៖  បន្ទាប់មកឈ្មោះស្រ៊ីម ពៅ

ក៖  ចុះទី8ឈ្មោះអីគេដែរអ៊ុំ ចុះពៅគេមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  បន្ទាប់មកនឹងពៅគេស្លាប់បាត់ហើយនឹងឈ្មោះស្រ៊ីម ហ៊ាយ ឈ្មោះស្រ៊ីម ពៅនឹងពៅគេ

កៈ ចឹងស្រ៊ីម ៣៧នឹង៣៧គេហោសអ៊ុំ ប៉ុន្តែអ្នកដែរស្លាប់នឹងអ៊ុំអត់បានរាប់បញ្ចូលទេ?

ខៈ អត់បានបញ្ចូលទេនឹង

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ អ្នកដែរស្លាប់នឹងមានឈ្មោះស្រ៊ីម ហ៊ុយ

កៈ ប៉ុន្តែគាត់ជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ គាត់ជាកូនទី6

កៈ ចឹងគាត់ជាកូនទី6ចឹងហោសអ៊ុំ?

ខៈ នឹងហើយនឹង

កៈ
ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីជាមួយបងប្អូនរបស់អ៊ុំកាលពីអ៊ុំនៅក្មេងៗដូចជាអ៊ុំធ្លាប់បាន
លេងឡឹក បាយឡ រីលេងបិទពួនអីទេ?

ខៈ កាលណុងដូចជាមិនអាចជាចាំបានទេនឹងដោយសារតែយើងនៅតូចៗហាស?

កៈ បាទអ៊ុំបាទ?

ខៈ ចឹងដឹងហើយប្រវត្តិរបស់ខ្ញុំដែរបានរៀនសូត្រនឹងបានថ្នាក់ទី8នឹង

កៈ ចឹងអ៊ុំបានរៀនថ្នាក់ទី8ហោសអ៊ុំ?

ខៈ នឹងហើយរៀនបានថ្នាក់ទី8នឹង

កៈ ប៉ុន្តែអ៊ុំរៀននៅសាលាណាដែរអ៊ុំ?

ខៈ ខ្ញុំបានរៀននៅសាលាថ្មគោលនឹង

កៈ បានរៀនតែមួយសាលានឹងតើហីអ៊ុំ?

ខៈ នឹងហើយរៀននៅសាលាថ្មគោលនឹងមួយទេ

កៈ ប៉ុន្តែចឹងអ៊ុំធ្លាប់មានមិត្តភក្តិជិតស្និទ្ធិណាដែរធំធាត់មកជាមួយគ្នាទេអ៊ុំ?

ខ៖ មានដែរនឹងមានតើ!

ក៖ ចុះអ៊ុំអាចប្រាប់ឈ្មោះមួយចំនួនដែរអ៊ុំអាចចាំបានទេអ៊ុំ?

ខ៖ មានឈ្មោះស្រ៊ី ត្រូវជាមិត្តភក្តិនឹង

ក៖ ចឹងមិញអ៊ុំនិយាយពី?

ខ៖ ប្រវត្តិដែរមានមិត្តភក្តិនឹង

ក៖ ចឹងកាលពីអ៊ុំនៅតូចៗជាមួយមិត្តភក្តិនឹងអ៊ុំធ្លាប់បានលេងអីជាមួយគ្នាដែរទេអ៊ុំ លក្ខណះថាជាអនុស្សាវរីយ៍ហាសអ៊ុំ?

ខ៖ មិត្តភក្តិនឹងបួសរៀន

ក៖ មិត្តភក្តិរៀនហោសអ៊ុំ?

ខ៖ បាទបួសរៀនស្គាល់គ្នាពេលដែរបានបួសរៀននឹង

ក៖ ប៉ុន្តែអ៊ុំមានធ្លាប់លេងអីជាមួយគ្នាដែរទេ?

ខ៖ អត់មានធ្លាប់លេងអីទេនឹង អត់ដែរលេងអីផងនឹងបួសរៀនជាមួយគ្នានឹងនៅឆ្នាំ1972នឹងហើយឆ្នាំ1973នឹងសឹកពីបួសរៀនវិញនឹង

ក៖ បាទចឹងហោសអ៊ុំ?

ខ៖ ពេលដែរសឹកពីបួសវិញនឹងបានទៅធ្វើជាយោធាខ្មែរក្រហមនឹង

ក៖ អ៎ូ!អ៊ុំបានធ្វើពីយោធាដែរហោសអ៊ុំ?

ខ៖ នឹងហើយបានធ្វើយោធាជំនាន់ខ្មែរក្រហមហាស

ក៖ ចឹងអ៊ុំគិតថាអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖ ខ្ញុំចេះតែភាសាខ្មែរទេនឹងសំរាប់ភាសាបរទេសនឹងមិនចេះទេ

ក៖ ប៉ុន្តែពេលណុងគេពេលណុងបានរៀនភាសាបារាំងដែរតើហីអ៊ុំ?

ខ៖ រៀនដែរបានតិចៗនឹងដែរ

កៈ ប៉ុន្តែអ៊ុំមិនសូវចេះទេ?

ខៈ នឹងហើយមើលដាច់បានតែតួអក្សរ តួអក្សរមើលស្គាល់បានខ្លះដែរ?

កៈ ចឹងមានន័យថាអ៊ុំចេះខ្លះៗដែរណាអ៊ុំ?

ខៈ ខ្ញុំបានចេះខ្លះៗដែរនឹង

កៈ ចឹងសំរាប់អ៊ុំមានចូលចិត្តលេងអីគេជាមួយប្អូនៗរបស់អ៊ុំដែរទេនឹង?

ខៈ
កាលពីដើមមកនឹងខ្ញុំមិនមែនជាអ្នករពឹសលេងអីទេលក្ខណះបាយឡឹកបាយឡអីនឹងមិនសូវជាអ្នក លេងទេនឹង

កៈ ប៉ុន្តែភាគច្រើនយើងចូលចិត្តលេងបិទពួន លេងគប់ឈូស
អីជាមួយបងប្អូនចឹងហាសអ៊ុំ?

ខៈ នឹងហើយៗៗត្រូវ

កៈ ប៉ុន្តែអ៊ុំមានធ្លាប់លេងដែរតើហីអ៊ុំ?

ខៈ ធ្លាប់លេងដែរបន្តិចបន្តួចៗៗនឹង

កៈ ចុះពួកកគាត់នៅណាដែរអ៊ុំបងប្អូនរបស់អ៊ុំសព្វថ្ងៃហាសអ៊ុំ?

ខៈ ពួកបងប្អូនរបស់ខ្ញុំនឹងពួកគាត់នៅជាមួយខ្ញុំដែរនឹង

កៈ ចឹងពួកគាត់មិនមាននៅខេត្តផ្សេងទេណាអ៊ុំ?

ខៈ អត់មាននៅខេត្តផ្សេងទេនឹង

កៈ ចឹងមានតែនៅកំពង់ចាមនឹងហើយនៅម្តុំៗនឹងទាំងអស់តែម្តងនឹង?

ខៈ នឹងហើយនៅនឹង

កៈ ចុះពួកគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ ធម្មតាទេកម្មករ នឹងកសិករដឹងស្រាប់ហើយនឹង

កៈ ចឹងពួកគាត់ធ្វើស្រែចំការណាអ៊ុំ?

ខ៖  នឹងហើយធ្វើស្រែចំការនឹងណាស់

ក៖  ចុះឪពុករបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឪពុករបស់ខ្ញុំនឹងមានឈ្មោះថា សៅ ស្រ៊ឹម

ក៖  ចុះដល់ឥឡូវនឹងគាត់អាប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខ៖  មកដល់ពេលបច្ចុប្បន្ននឹងគាត់អាយុ85ឆ្នាំហើយ

ក៖  ចឹងមានដឹងថាគាត់កើតនៅឆ្នាំណាអ៊ុំមានដឹងទេអ៊ុំ?

ខ៖  កើតនៅឆ្នាំដូចជា..........!

ក៖  មិនមែនទេគាត់នៅឆ្នាំ1933?

ខ៖  អូ៎!គាត់កើតនៅឆ្នាំ1932

ក៖  ចឹងគាត់អាយុ32ឆ្នាំចឹងមានន័យថាគាត់អាយុ85ឆ្នាំ?

ខ៖  នឹងហើយគាត់អាយុ85ឆ្នាំនឹង

ក៖  ចឹងបើគាត់កើតនៅឆ្នាំ1932គាត់អាយុ86ឆ្នាំអ៊ុំ?

ខ៖  ចឹងហោសចឹង គាត់កើតនៅឆ្នាំ1932

ក៖  ចឹងគាត់អាយុ86ឆ្នាំអ៊ុំ ចឹងគាត់កើតនៅណាដែរអ៊ុំ?

ខ៖  គាត់កើតនៅភូមិវាលខ្សាច់នឹងដែរនឹង

ក៖  ចុះម្តាយរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ម្តាយរបស់គាត់ហោស?

ក៖  អត់ទេម្តាយរបស់អ៊ុំហាស?

ខ៖  ម្តាយរបស់ខ្ញុំនឹងមានឈ្មោះស៊ន ហ៊ាង

ក៖  ប៉ុន្តែពួកគាត់ដូចជាបងប្អូនគ្នាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖  គាត់អាយុស្តួរគ្មានឹង

កៈ អូ!ពួកគាត់អាយុស្តរគ្នាដែរហោសអ៊ុំ
ចឹងមានន័យថាគាត់កើតនៅក្នុងឆ្នាំ1932ដូចគ្នាទៅ?

ខៈ បាទៗៗនឹងហើយ

កៈ ចឹងសំរាប់ឪពុករបស់អ៊ុំនឹងគាត់ធ្វើអីគេដំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ជាកម្មករនឹង កសិករនឹងដែរ

កៈ ចឹងមានន័យថាគាត់ធ្វើតែមួយនឹងទេណអ៊ុំ?

ខៈ បាទគាត់ធ្វើតែមួយនឹង

កៈ ចុះឪពុករបស់អ៊ុំនឹងគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខៈ ឪពុករបស់អ៊ុំខ្ញុំនឹងដូចជាមិនសូវជាកាចទេនឹង

កៈ ចឹងគាត់ស្លូតដែរហោសអ៊ុំ ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ធ្វើជាកសិករដែរនឹងណាស់ នឹងកម្មករដែរនឹង

កៈ ចុះគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខៈ គាត់ស្លូតណាស់ម្តាយរបស់ខ្ញុំនឹង

កៈ
ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីជាឪពុកម្តាយរបស់អ៊ុំដែរអ៊ុំគិតថាចងចាំមិនភ្លេចហាសអ៊ុំ?

ខៈ មានចងចាំអីទេមានចងចាំតែធំឡើងនឹងគាត់បានអោយទៅរៀនសូត្រនឹង
នៅសាលាវត្តថ្មគោលនឹង ណាស់

កៈ បាទអ៊ុំ
ចុះម្តាយរបស់អ៊ុំនឹងគាត់មានដែរប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេអ៊ុំ?

ខៈ អត់ដែរមានប្រាប់ពីប្រវត្តិអីទេ

កៈ ថាពីមុនគាត់ធ្វើការ រឺមួយក៏រកស៊ីអីមិនដែរប្រាប់ទេហោសអ៊ុំ?

ខៈ ដូចជាមិនដែរប្រាប់អីទេ

កៈ ចុះនៅពេលដែរឪពុករបស់អ៊ុំវិញ?

ខៈ ឪពុករបស់ខ្ញុំនឹងក៏គាត់មិនដែរប្រាប់ដែរនឹង
គាត់គ្រាន់តែប្រាប់ថាពេលដែរគាត់ធំឡើងកាលណាគាត់បានទៅរៀននឹង

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ រៀននៅសាលាវត្តណោះនឹង

កៈ បាទអ៊ុំចុះយាយតាខាងឪពុកអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខៈ យាយតាខាងឪពុកម្ដាយរបស់ខ្ញុំនឹងស្គាល់

កៈ យាយតាខាងឪពុកមានឈ្មោះអីគេដែរអ៊ុំ?

ខៈ យាយតាខាងឪពុកនឹងមានឈ្មោះសៅ
ភ្លេចថាឈ្មោះអីគេសៅបាត់ហើយនឹងដឹងតែសៅនឹង

កៈ ចុះយាយវិញអ៊ុំ?

ខៈ យាយឈ្មោះយាយគាង

កៈ នឹងខាងឪពុកណអ៊ុំ?

ខៈ បាទៗៗនឹងឪពុកម្ដាយខាងឪពុករបស់ខ្ញុំនឹង

កៈ ចុះឪពុកម្ដាយខាងម្ដាយវិញអ៊ុំ?

ខៈ ឪពុកម្ដាយខាងម្ដាយវិញយាយឈ្មោះយាយងាណ

កៈ ចុះតាវិញអ៊ុំ?

ខៈ តានឹងឈ្មោះតាសៀវ

កៈ ប៉ុន្តែអ៊ុំនៅមានចងចាំតទៀតទេអ៊ុំ?

ខៈ អត់មានចងចាំទេ

កៈ ចុះយាយតាខាងឪពុក នឹងយាយតាខាងម្ដាយពួកគាត់នៅណាដែរអ៊ុំ?

ខ៖  គាត់នៅខាងភូមិបាល្ងាំ

ក៖  ប៉ុន្តែមួយនឹងដូចជានៅខាងឪពុករឺមួយក៏នៅខាងម្ដាយដែរអ៊ុំ?

ខ៖  ខាងម្ដាយនឹង

ក៖ ចុះខាងឪពុកវិញអ៊ុំ?

ខ៖  ខាងឪពុកនឹងខ្ញុំក៏មិនស្គាល់ដែរនឹង

ក៖  អត់ដឹងថាគាត់អ្នកនៅណាដែរទេហោសអ៊ុំ?

ខ៖  បាទៗមិនដឹងទេនឹង

ក៖  ចុះគ្រួសាររបស់អ៊ុំនឹងមករស់នៅនឹងយូរនៅអ៊ុំ?

ខ៖  ពេលដែរបច្ចុប្បន្នរឺយ៉ាងម៉េចដែរ?

ក៖  ចង់និយាយថាក្រុមគ្រួសាររបស់អ៊ុំនឹងមករស់នៅខេត្តនឹងយូរនៅអ៊ុំ?

ខ៖  បើតាមខ្ញុំដឹងក្ដីមកគឺរស់នៅខេត្តកំពង់ចាមនឹងតែម្ដងនឹង

ក៖  ចឹងមានន័យថាអស់ប្រហែលជាហុកសិបឆ្នាំនឹងហើយណា?

ខ៖  បាទនឹងហើយ

ក៖  មានពីមុននឹងទៀត?

ខ៖  បាទមានយូរដែរហើយនឹង

ក៖  ចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ចឹងបងប្អូនកូនចៅក៏អត់មានដែរណាអ៊ុំ?

ខ៖  បាទអត់មានទេនឹង

ក៖  ចុះភរិយារបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  គាត់មានឈ្មោះឈន ភេត

កៈ
ចុះអ៊ុំមានចងចាំថាអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់អ៊ុំនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខៈ អត់បានចងចាំផងកាលពីជំនាន់ណុងយើងរៀបចំនៅក្នុងជំនាន់ពលពតនឹង

កៈ នៅក្នុងឆ្នាំប៉ុន្មានដែរអ៊ុំ?

ខៈ នៅក្នុងឆ្នាំ1977នឹង

កៈ ចឹងមានន័យថាអ៊ុំការអស់រយះពេល41ឆ្នាំហើយនឹង?

ខៈ បាទនឹងហើយនឹង

កៈ មែនទេអ៊ុំ?

ខៈ បាទនឹងហើយចឹងប្រហែលជាប៉ុណ្ណឹង

កៈ
ចុះនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំរៀបចំដោយចិត្តឯងរឺមួយក៏ម្តាយឪពុករបស់ អ៊ុំជាអ្នករៀបអោយដែរអ៊ុំ?

ខៈ កាលពីជំនាន់ណុងអើរ………..!

កៈ ឪពុកម្តាយជាអ្នករៀបអោយហោសអ៊ុំ?

ខៈ ឪពុកម្តាយនឹងស្ដីដណ្ដឹងដែរនឹង

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ នឹងនៅជំនាន់ពលពតនឹងណាស់ នៅជំនាន់ខ្មែរក្រហមនឹងណាស់គេបានរៀបចំ5-6គូរហោស

កៈ អូគេជាអ្នករៀបចំអោយហោសអ៊ុំ?

ខៈ នឹងហើយគេធ្វើអោយតើ!នឹង

កៈ
ប៉ុន្តែពេលដែររៀបចំនឹងដូចជាយើងមិនដែរបានឃើញសោះរឺក៏យើងបានឃើញគ្នាហើយៗ
ៗនឹង?

ខៈ យើងបានឃើញគ្នាដែរនឹង

កៈ ប៉ុន្តែពេលណុងយើងស្រលាញ់គ្នាហើយមែនទេអ៊ុំ?

ខៈ បាទស្រលាញ់ហើយតើ!

កៈ ប៉ុន្តែយើងសុំគេរឺមួយក៏ចាប់យកអោយតែម្តងនឹង?

ខៈ អត់ទេអត់មានគេចាប់ទេ

កៈ យើងសុំគេហោស?

ខៈ
ណុងហើយយើងសុំគេនឹងឪពុកម្តាយចូលស្តីដណ្តឹងអោយនៅទូលំទូលាយនៅឡើយទេនឹ
ង មិនទាន់ថាយ៉ាប់ទាំងគូរទេណាស់

កៈ ចុះមានជាជំនូនថ្លៃទឹកដោះទេពេលដែរអ៊ុំចូលស្តីដណ្តឹងអ៊ុំស្រីចឹងហាសអ៊ុំ?

ខៈ អត់មានទេនឹងកាលពីជំនាន់ណុង

កៈ អ៎ូ!ចឹងគ្រាន់តែរៀបចំធម្មតាទេហោសអ៊ុំ?

ខៈ នឹងហើយ

កៈ ប៉ុន្តែមានហូបជាតុជាអីដែរតើហីអ៊ុំ?

ខៈ
អត់មានទេកាលណុងគ្រាន់តែទៅស្តីដណ្តឹងចឹងទៅអោយទៅប្តេជ្ញចិត្តនៅនឹងកន្លែងនឹង

កៈ ប៉ុន្តែគេមានជប់លាងអីអត់អ៊ុំ រឺមួយក៏អត់ទេ?

ខៈ មានដែរគេមានជប់លាងអីដែរនឹង

កៈ ជប់លាងលក្ខណៈថាដូចជាកាប់គោ កាប់ជ្រូកអីខ្លះៗចឹងហោសអ៊ុំ?

ខ៖ នឹងហើយនឹងវាចឹង

ក៖
ចុះអ៊ុំអាចប្រាប់ខ្ញុំពីពេលដំបូងដែរអ៊ុំបានជួបជាមួយអ៊ុំស្រីនៅពេលណាហើយបានជួបនៅណាដែរចឹង ហាសអ៊ុំ?

ខ៖ កាលពីជំនាន់ណុងដើរទៅ លក្ខណះថាគេហៅដើរទៅធ្វើកងចល័តអីចឹងណាស់

ក៖ បាទអ៊ុំចឹង?

ខ៖ ប៉ុន្តែនៅឆ្នាំ1978បានខ្មែរក្រហមពួកពលពតគេរៀបចំទាំងគូរតែម្តងនឹង
កាលពីនៅឆ្នាំ1977នឹង នៅឡើយទេនឹង
ហើយវានៅចុងឆ្នាំនឹងចុងឆ្នាំ1977នឹងគេចូលស្តីដណ្តឹងដែរប៉ុន្តែគេរៀបទាំងគូរដែរនឹង

ក៖ បាទចឹងហោសអ៊ុំ?

ខ៖ ចាចឹងនៅពេលនោះ

ក៖ ចឹងអ៊ុំគិតថាអ៊ុំមានចេះអានរឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរទេអ៊ុំ?

ខ៖ បញ្ហាអក្សរខ្មែរដូចថាខ្ញុំចេះមើលដាច់នឹងអាចមើលបានដែរ

ក៖ ចឹងអ៊ុំបានរៀននៅថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំបានរៀននៅថ្នាក់ទី8នឹង

ក៖ អូ៎!ចឹងអ៊ុំរៀនបានថ្នាក់ទី8 ចឹងអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖ ខ្ញុំមិនបានចេះភាសាអិក្រៅពីភាសាខ្មែរទេនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បានធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ុំហាស?

ខ៖ សួរពីពេលបច្ចុប្បន្ននឹងមែន?

ក៖ បាទអ៊ុំពេលឥឡូវនឹង?

ខ៖ ពីពេលបច្ចុប្បន្ននឹងមានអីក្រៅពីខាងសំណង់
ពីមុននឹងទទួលការងារគេធ្វើសំណង់ហាស

កៈ ចុះពីមុននឹងអ៊ុំមានបានធ្វើអីទេអ៊ុំ?

ខៈ ពីមុននឹងមានអីធ្វើស្រែធ្វើចំការនឹង

កៈ អូ៎!បាទអ៊ុំ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរទៅអ៊ុំ?

ខៈ អត់មានការផ្លាស់ប្តូរស្អីទេនឹង

កៈ ចឹងតាំងពីក្មេងរហូតមកដល់ពេលនេះនឹងអត់មានការផ្លាស់ប្តូរអីទេ?

ខៈ នឹងហើយមិនមានការផ្លាស់ប្តូរអីទេនឹង

កៈ ទាំងជីវភាព នឹងទាំងសុខភាពអីចឹងហាសអ៊ុំ?

ខៈ នឹងហើយបញ្ហាសុខភាពនឹងធម្មតាទេ

កៈ ចឹងធម្មតាទេណាអ៊ុំ អ៊ុំនៅមានកំលាំងនៅឡើយទេហោសអ៊ុំ?

ខៈ នឹងហើយបើនិយាយាពីបញ្ហាជីវភាពនឹងវារៀងទូលំទូលាយតិចដែរនឹង

កៈ បាទចឹងល្អជាងមុនណាអ៊ុំ?

ខៈ នឹងហើយចាប់ពីណុងមកដល់ឥឡូវនឹង

កៈ ចុះអ៊ុំគិតថាអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរទៅអ៊ុំ?

ខៈ ម្ហូបនៅស្រុកខ្មែរយើងនឹងមានអីក្រៅពីម្ហូបសំលម្ជូរ នឹងឆាអីនឹង

កៈ ចុះអ៊ុំកាលពីនៅក្មេងនឹងអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរអ៊ុំ?

ខៈ អត់ដែរលេងល្បែងប្រជាប្រិយ៍អីផងនឹង

កៈ ចោលឈូង ទាញព្រាត លាក់កន្សែងអីក៏មិនដែលដែរ?

ខៈ អត់ដែរទេនឹង

កៈ ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខៈ និយាយរឿងច្រៀងវិញដូចថាវាមិនចេះតែម្តងទៅនឹង

កៈ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងទេអ៊ុំចឹង?

ខ៖  បើបទចំរៀងចូលចិត្តស្តាប់ដែរ

ក៖  លក្ខណៈថាបទសម័យរឺមួយក៏បទបុរាណដែរអ៊ុំ?

ខ៖  ចូលចិត្តស្តាប់បទសម័យបុរាណពីដើមនឹង

ក៖  ចឹងបទពីដើមណាអ៊ុំ?

ខ៖  នឹងហើយបទជំនាន់លោកតាស៊ិនស៊ីសាម៉ុត

ក៖  ចុះអ៊ុំចូលចិត្តស្តាប់ធិមស្តាប់អីទេអ៊ុំ?

ខ៖  ធិមចូលចិត្តស្តាប់ដែរតើ!នឹង

ក៖  ចុះលក្ខណៈថាល្ខោនយីកេអីអ៊ុំចូលចិត្តស្តាប់ នឹងចូលចិត្តមើលទេអ៊ុំ?

ខ៖  បាទចូលចិត្តស្តាប់នឹងមើលនឹងដែរ

ក៖  ភាគច្រើនមើលតាមទូរទស្សន៍ហីអ៊ុំ?

ខ៖  នឹងហើយមើលតាមទូរទស្សន៍នឹងហើយ

ក៖

ចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ទាំងបងប្អូនអីក៏អត់មានដែរហោសអ៊ុំ?

ខ៖  បាទអត់មានទេ

ក៖  លក្ខណៈភ្លេងពិនពាត ភ្លេងខ្មែរ ភ្លេងសៀម អកកន្ទុងអីក៏មិនមានដែរហោសអ៊ុំ?

ខ៖  បាទអត់មានទេនឹង

ក៖  ចុះផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខ៖  ផ្ទះរបស់ខ្ញុំនឹងតាំងពីក្មេងមក.........!

ក៖  ពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដែរហោសអ៊ុំ?

ខ៖ អូ៎!តាំងពីក្មេងនឹងផ្ទះស្បូវមួយខ្នងនឹង

ក៖ ប៉ុន្តែដល់ពេលឥឡូវនឹង?

ខ៖ ដល់ពេលឥឡូវនឹងផ្ទះបាន3ខ្នងដែរនឹង

ក៖ ចឹងមានន័យថាឥឡូវនឹងផ្ទះធំជាងមុនមែនទេអ៊ំ?

ខ៖ នឹងហើយផ្ទះធំជាងមុននឹងហើយ

ក៖ ចុះផ្ទះរបស់អ៊ំនឹងគិតថាអ៊ំជាអ្នកសាងសងដោយខ្លួនឯង
រឺមួយក៏អ៊ំជួលគេជាអ្នកធ្វើដែរអ៊ំ?

ខ៖ ផ្ទះនឹងខ្ញុំជាអ្នកសាងសងខ្លួនឯងតែម្តងនឹង

ក៖ អូ៎!អ៊ំចេះធ្វើផ្ទះហោសអ៊ំ?

ខ៖ បាទខ្ញុំចេះតើ!

ក៖ ចុះនរណាគេជាអ្នកបង្រៀនអ៊ំដែរ?

ខ៖ អត់មាននរណាគេបង្រៀនទេ ដើរទៅធ្វើតាមគេចឹងទៅមានគំនិតធ្វើខ្លួនឯង

ក៖ គេហៅថាបែកគំនិតធ្វើខ្លួនឯងនឹង?

ខ៖ នឹងហើយបែកគំនិតធ្វើដោយខ្លួនឯងនឹង

ក៖ ចឹងមមានន័យថាអ៊ំជាអ្នកធ្វើសំណង់ដែរ?

ខ៖ បាទនឹងហើយ

ក៖ ចុះគិតថាផ្ទះរបស់អ៊ំនឹងគិតថាគេប្រើឧបករណ៍គេខ្លះដែរសំរាប់ធ្វើផ្ទះនឹងចឹងហាសអ៊ំ?

ខ៖ ផ្ទះនឹងគេប្រឧបករណ៍ដូចជាផ្ទះឈើនឹងគេមានកាំបិត មានពូថៅ មានពន្លាក
រណានុងហើយនឹងប៉ុណ្ណឹង

ក៖ ចុះផ្ទះអ៊ំឥឡូវនឹងខាងក្រោមអីនឹងគេធ្វើពី?

ខ៖ ខាងក្រោមនឹងគេជីកគ្រឹសដាក់ថ្មនឹង

កៈ  អូគេជីកគ្រឹសដាក់ថ្មហោស មានជាកំបោមានជាអីចឹងទៅហោសអ៊ុំ?

ខៈ  បាទនឹងហើយមានចឹង

កៈ  ចុះអ៊ុំគិតថាជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខៈ  ខ្ញុំខាងជាងនឹងខ្ញុំស្ទាត់ជំនាញខាងផ្ទះនឹងតែម្តងនឹង

កៈ
ចុះកាលពីមុននឹងម្តាយឪពុករបស់អ៊ុំនឹងធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំផ្សេងដែរទេដូចជា
វេញវល្លិ៍ ធ្វើផ្តៅ កូរស្ករ ធ្វើជាកន្ទេលអញ្ចឹតអីចឹងហាសអ៊ុំ?

ខៈ  អត់មានទេ នៅស្រុកខ្ញុំនឹងអត់មានមានតែឡើងត្នោត

កៈ  ប៉ុន្តែអ៊ុំចេះឡើងត្នោតមែនទេអ៊ុំ?

ខៈ  បាទចេះដែរនឹង

កៈ  ប៉ុន្តែនៅពេលដែរអ៊ុំឡើងមកអ៊ុំយកមកកូរស្ករមែនទេអ៊ុំ?

ខៈ  ពេលដែរឡើងយកមករំងាស់វា

កៈ  ចឹងមានន័យថាអ៊ុំចេះកូរស្ករត្នោតហើយចឹងនោះ

ខៈ  បាទចេះតើ!

កៈ  ចុះបើនិយាយពីកាលលំបាកវិញអ៊ុំគិតថា
តាំងពីក្មេងរហូតមកដល់ពេលនេះគិតថាអ៊ុំធ្លាប់ជួបការ លំបាកអីគេខ្លះដែរអ៊ុំ?

ខៈ  ក្នុងការលំបាកនឹងដូចថាលំបាកតែកូនរបស់ខ្ញុំនឹងនៅតូចៗនឹង
ពិបាករកស៊ីចិញ្ចឹមកូននឹង

កៈ  នឹងកាលពីអ៊ុំមានកូននៅតូចៗណាអ៊ុំ?

ខៈ  បាទនឹងហើយ

កៈ  ចុះកាលពីក្មេងអ៊ុំមានធ្លាប់ជួបការលំបាកអីទេអ៊ុំ
ដោយសារតែខ្ញុំកាលពីជំនាន់អ៊ុំនឹងដូចជា..........?

ខ៖ កាលនៅពីក្មេងនឹងជួបកាលលំបាកចុះកាលពីជំនាន់ណុងវាជំនាន់ស្រុកសង្គ្រាមនឹង

ក៖ បាទត្រូវអ៊ុំ?

ខ៖ ដូចថាមិនបានរៀនសូត្រនឹង

ក៖ ប៉ុន្តែកាលណុងជំនាន់អ៊ីសារ៉ាក់ហីអ៊ុំ?

ខ៖ ទេអ៊ីសារ៉ាក់មុននឹង

ក៖ ចឹងជំនាន់លុនណុលហីអ៊ុំ?

ខ៖ ជំនាន់លុនណុលនឹងខ្មែរក្រហមនឹងណាស់

ក៖ អូ!ប៉ុន្តែគេអោយយើងធ្វើអីទៅអ៊ុំ?

ខ៖ ជំនាន់ណុងនៅកុមារតូចនឹងនៅរៀននឹង

ក៖ គេអោយយើងរៀនណាអ៊ុំ?

ខ៖ បាទយើងនៅរៀននឹង

ក៖ ប៉ុន្តែគេមិនបានចាប់យើងទៅធ្វើអីផ្សេងៗទេណាអ៊ុំ?

ខ៖ អត់មានទេយើងនៅតូចនឹង
យើងរៀនពេលដែររៀនហើយបានយើងទៅបួសនៅសាលានឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ នៅបួសនៅវត្តនឹងបួសបាន2ព្រះវស្សាដែរ

ក៖ អូអ៊ុំមានធ្លាប់បួសដែរហោសអ៊ុំ?

ខ៖ នឹងហើយធ្លាប់ដែរនឹង

ក៖ ពេលដែរអ៊ុំបួសនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ប្រហែលជានៅឆ្នាំ1973នឹង ប្រហែលជាអាយុ17ឆ្នាំអីនឹង

ក៖ ចឹងមានន័យថារៀងធំដែរហើយណាអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ រហូតដល់ពេលឆ្នាំ1975នឹងបានពលពតចូលមកហើយណាអ៊ុំ?

ខ៖ នឹងហើយនៅពេលឆ្នាំ1973នឹងខ្ញុំបួសមើលតាំងពីឆ្នាំ1972នឹង

ក៖ រហូតដល់ឆ្នាំណាដែរទៅអ៊ុំ?

ខ៖ បួសបាន2ព្រះវស្សានឹង

ក៖ ចឹងមានន័យថាឆ្នាំ1974នឹង?

ខ៖ បាទបានតែប៉ុណ្ណឹងទេណាស់

ក៖ ចឹងប៉ុណ្ណឹងណាអ៊ុំ?

ខ៖ នឹងបន្ទាប់មកក៏សឹកទៅ បន្ទាប់ពីសឹកនឹងមកចូលទៅធ្វើខ្មែរក្រហមតែម្ដងនឹង

ក៖ ចុះពេលណុងដូចជាគេបង្ខំអោយអ៊ុំសឹក រឺមួយក៏អ៊ុំចង់សឹកខ្លួនឯងដែរអ៊ុំ?

ខ៖ ពេលណុងយើងចង់សឹកខ្លួនឯងតើ គ្មានអ្នកបង្ខំទេនឹង

ក៖ អ៎ូ!ចឹងយើងធ្វើដោយខ្លួនឯងទេ?

ខ៖ នឹងហើយនឹកឃើញថាពេលដែរបួសទៅក៏មិនបានរៀនទេនឹងគេដែរនឹង

ក៖ ចឹងអត់បានរៀនទេហោសអ៊ុំ?

ខ៖ រវល់តែរត់លូននឹងរំសេវនឹង

ក៖
ចុះពេលដែរចូលដល់ជំនាន់ពលពតខ្មែរក្រហមនឹងពេលណុងអ៊ុំធ្វើជាទាហ៊ានហើយមែនទេអ៊ុំ?

ខ៖ ពេលណុងធ្វើជាយោធា

ក៖ អ៎ូ!ធ្វើយោធាហោសអ៊ុំ?

ខ៖ នឹងហើយធ្វើជាយោធាខ្មែរក្រហមនឹងហើយ

កៈ ប៉ុន្តែពេលណុងគេអោយអ៊ុំកាន់នៅខាងណាដែរទៅអ៊ុំ?

ខៈ អត់មានកាន់ទេនឹង មិននៅខាងអីទេពីព្រោះខ្ញុំនៅតូចដែរនឹង
មានកាន់តែកាំងភ្លងតាមតែគេដែរនឹង

កៈ ប៉ុន្តែណុងអ៊ុំនៅណាដែរអ៊ុំ?

ខៈ ពេលណុងនៅខេត្តកំពង់ចាមយើងនឹងដែរនឹង

កៈ ប៉ុន្តែគេមិនមានអោយអ៊ុំធ្វើអីផ្សេងទេហីអ៊ុំ?

ខៈ មិនបានធ្វើនិនាការធំៗអីគេទេនឹង

កៈ ចុះសំរាប់ម្តាយឪពុករបស់អ៊ុំនឹងគេអោយធ្វើអីគេដែរទៅអ៊ុំ?

ខៈ ពេលណុងគាត់ធ្វើជាកម្មករ
នឹងកសិករដដែលនឹងណាស់ធ្វើស្រែធ្វើចំការអីដដែរនឹងណាស់

កៈ ចុះបងប្អូនវិញអ៊ុំ?

ខៈ បងប្អូនក៏នៅចឹងដែរដូចគ្នានឹង

កៈ ប៉ុន្តែគេមានជំលាសអោយនៅឆ្ងាយពីអ៊ុំអីទេអ៊ុំ?

ខៈ ថាម៉េចគេ?

កៈ ចង់និយាយថាគេមានជំលាសអោយទៅឆ្ងាយពីឪពុកម្តាយអីទេ?

ខៈ អត់មានទេនឹង

កៈ ចឹងគ្រួសាររបស់អ៊ុំនឹងគឺនៅជុំគ្នាតែម្តងនឹងហោសអ៊ុំ?

ខៈ បាទគឺនៅជុំគ្នាតែម្តងនឹង

កៈ ចឹងមានតែអ៊ុំមួយទេដែរនៅឆ្ងាយពីគេ?

ខៈ នឹងហើយបែកតែខ្ញុំមួយទេដែរនៅយោធាធ្វើជាទាហាននឹងណាស់

កៈ ចឹងមានន័យថាអោយពួកគាត់ធ្វើការធម្មតាៗនៅផ្ទះហើយណាអ៊ុំ?

ខ៖ ណុងហើយចឹង

ក៖ ចុះរបបអាហារអីអ៊ុំខុសពីគេដែររឺមួយក៏ដូចគេដែរអ៊ុំ?

ខ៖ ដូចតែគេចឹងគេហូបអីយើងហូបនឹងដែរនឹង

ក៖ ប៉ុន្តែភាគច្រើនរបបអាហារគេហូបអីគេដែរទៅអ៊ុំ
កាលណុងនៅជំនាន់ពលពតហាសអ៊ុំ?

ខ៖ ជំនាន់ណុងខ្ញុំនៅយោធានឹងហូបតាមអង្គភាពនឹង

ក៖ ប៉ុន្តែពេលណុងហូបបាយហីអ៊ុំ?

ខ៖ ហូបបាយតើ!នៅក្នុងយោធានឹងមិនទាន់មានបបរអីនឹងទេ បើបបរនៅតាមមូលដ្ឋាន

ក៖ ចុះនៅពេលណុងអ៊ុំមានជួបកាលលំបាកអីទេអ៊ុំ?

ខ៖ វាជួបការលំបាកដែរនឹងទៅធ្វើជាកងទ័ពនឹងវាមានជួបការលំបាកដែរនឹង

ក៖ ជួបយ៉ាងម៉េចវិញអ៊ុំអាចប្រាប់បានខ្លះៗដែរទេអ៊ុំ?

ខ៖ ជួបការលំបាកភ័យខ្លាចអារឿងគ្រាប់រំសេវអីនឹង
ខ្លាចត្រូវគ្រាប់ស្លាប់ចោលឪពុកម្តាយអីចឹងទៅ ណាស់
គ្រាន់តែគិតព្រួយបារម្ភណ៍អីចឹងកាលពីស្រុកកើតសង្គ្រាមនឹង

ក៖
ចុះរហូតទាល់តែដាច់ពលពតនឹងអ៊ុំនៅតែធ្វើជាកងទ័ពដដែររឺមួយម៉េចដែរអ៊ុំរឺអ៊ុំធ្វើជាអីផ្សេងដែរអ៊ុំ?

ខ៖ ជំនាន់ពីឆ្នាំដាច់1979នឹងដល់ឆ្នាំ1984នឹងធ្វើជាកងទ័ពរដ្ឋកម្ពុជា

ក៖ ចឹងហោសអ៊ុំ?

ខ៖ មិនបានមួយឆ្នាំទេ
បានតែ6ខែទេនឹងនឹកប្រពន្ធកូនពេកក៏ឈប់ហើយពេលណុងគេចាប់បង្ខំដែរ

ក៖ ប៉ុន្តែពេលណុងគេចាប់យកអ៊ុំទៅធ្វើនៅណាដែរអ៊ុំ?

ខ៖ ចាប់ទៅធ្វើនៅគេហៅថាទូលលៅ

ក៖ ទូលលៅនឹងនៅខេត្តកំពង់ចាមយើងនឹងតើហីអ៊ុំ?

ខ៖ ទូលៅនឹងនៅខេត្តកំពង់ចាមយើងនឹងតើ
បើយាយពីស្រុកវិញនៅស្រុកចំការលើយើងនឹង

ក៖ ប៉ុន្តែប្រពន្ធកូនរបស់អ៊ុំនៅណាដែរទៅអ៊ុំ?

ខ៖ ប្រពន្ធកូននៅនឹងដែរតើនៅផ្ទះនឹង

ក៖ អូ៎!ចឹងមានន័យថាពួកគាត់នៅផ្ទះនឹងទេ?

ខ៖ បាទគាត់ស្នាក់នៅនឹង

ក៖ ប៉ុន្តែគាត់ធ្វើជាស្រែចំការដែរហោសអ៊ុំ?

ខ៖ បាទពេលណុងគ្មានធ្វើអីទេធ្វើតែស្រែចំការនឹង

ក៖ ដោយសារតែពេលណុងវាអស់សង្គ្រាមហើយណាអ៊ុំ?

ខ៖ ពេលណុងនៅសង្គ្រាមពេញតែម្តងនឹង

ក៖ អូ៎!ពេលណុងសង្គ្រាមនៅពេញម្តងទៀតហោសអ៊ុំ?

ខ៖
បាទសង្គ្រាមម្តងទៀតនឹងសង្គ្រាមឆ្នាំ1979នឹងវៃជាមួយពលពតនឹងរហូតមកដល់ឆ្នាំ1990នឹង

ក៖ នរណាគេដែរជាអ្នកវៃអ៊ុំវៀតណាមមែនអ៊ុំ?

ខ៖ វៃនេះមិនជំនាន់ឆ្នាំ1979នឹងមិនវៀតណាមមកចូល

ក៖ លក្ខណះថាចូលរំដោះមែនទេអ៊ុំ?

ខ៖ នឹងហើយចូលមករំដោះខ្មែរក្រហមយើងនឹង
បាទចូលរំដោះវៃខ្មែរក្រហមនឹងរហូតមកដល់ឆ្នាំ1993

ក៖ នឹងបានសន្តិភាពហើយណាអ៊ុំ?

ខ៖ បានមកដល់ឆ្នាំ1993នឹងបានសន្តិភាពហើយនឹង

ក៖ រហូតមកដល់ឥឡូវនឹងមក?

ខ៖ រហូតមកដល់ពេលដែរបច្ចុប្បន្ននឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ
ការលំបាកដែរអ៊ុំលំបាកពេលទាំង
អស់ចឹងហាសដូចជាអ៊ុំជំនះឧបសគ្គមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖
ការធ្វើជាសង្គ្រាមពីឆ្នាំ1984នឹងនៅវៃជំនាន់រដ្ឋកម្ពុជានឹងនៅឆ្នាំ1984នឹងចេះតែព្រួយបារម្ភ
ណ៍រឿងធ្វើ សង្គ្រាមខ្លាចស្លាប់ចោលប្រពន្ធកូនអីចឹងទៅណាស់
យើងព្រួយបារម្ភណ៍តែប៉ុណ្ណឹងទេ

ក៖ អូ៎!បាទអ៊ុំ
ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ
ទៅអ៊ុំ?

ខ៖ បើគិតមើលទៅនៅក្នុងឆាកជីវិតរបស់ខ្ញុំនឹងមិនមានការសប្បាយសោះតែម្តងនឹង

ក៖ នៅពេលដែរអ៊ុំការកូនរឺមួយអ៊ុំជួបជុំក្រុមគ្រួសារដែរធ្វើអោយអ៊ុំសប្បាយចឹងហាសអ៊ុំ?

ខ៖ ដល់ពេលមកដល់ឥឡូវនឹងទៅស្រុកវាសន្តិភាពទៅនឹង វានៅតែមានការលំបាកចឹង

ក៖ ប៉ុន្តែវាមានតិចតួចហើអ៊ុំ?

ខ៖ នឹងហើយនៅក្នុងជីវភាពរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែមិនមានអីច្រើនទេណាអ៊ុំដោយសារតែវាលែងមានសង្គ្រាមហើយនឹង?

ខ៖ បាទពីព្រោះវាលែងមានសង្គ្រាមហើយនឹង
វាមានបញ្ហាដូចថាចិញ្ចឹមជីវិតក្រុមគ្រួសារនឹងណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ វាមានការលំបាកចឹងពីព្រោះនឹង

ក៖ ចុះអ៊ុំកាលពីក្មេងហាស
កាលអ៊ុំនៅរៀននឹងអ៊ុំធ្លាប់មានក្ដីស្រម៉ៃទេថាធំឡើងនឹងអ៊ុំចង់ធ្វើស្អីដែរទេអ៊ុំ?

ខ៖ អត់មានផងនឹងអត់មានពីការសប្បាយអីដូចជាគ្មានទេ

ក៖ ប៉ុន្តែអ៊ុំធ្លាប់មានក្ដីស្រម៉ៃដែរទេអ៊ុំ?

ខ៖ មានក្ដីស្រម៉ៃដែរនឹង

ក៖ កាលនៅពីតូចហាសអ៊ុំ?

ខ៖ ពីតូចនឹងធ្វើអីនឹងហោស?

ក៖ បាទថាអ៊ុំចង់ធ្វើអីមួយចឹងហាសអ៊ុំលក្ខណះថា ធ្វើជាទាហ៊ាន រឺគ្រូពេទ្យចឹងហាសអ៊ុំ?

ខ៖ វាដូចកាលនោះនឹងវាគ្មានក្ដីស្រម៉ៃថាចង់ធ្វើជាស្អីៗសោះនឹងណាស់
ដូចថាគ្មានគំនិតនឹងដុះនឹង ណាស់វាចឹង

ក៖
ចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខ៖
ឥឡូវនឹងខ្ញុំដែរចំណាស់នឹងហើយខ្ញុំមានបញ្ហាចង់អោយកូនចៅរបស់ខ្ញុំនឹងបានរៀនសូត្រ

ក៖ ចឹងហោសអ៊ុំអោយពួកគាត់ខំរៀនសូត្រ?

ខ៖ នឹងហើយរៀនអោយបានជ្រៅជ្រះកុំអោយាមនបញ្ហាដូចរូបខ្ញុំនឹង

ក៖ បាទអ៊ុំ
ចុះបើសិនជាចង់អោយពួកគាត់ជៀរៀងវិញតើអ៊ុំចង់អោយពួកគាត់ជៀសវៀងអីគេដែរអ៊ុំ?

ខ៖ លក្ខណះពិបាកនិយាយដែរនឹង

ក៖ អត់ទេលក្ខណះថាជៀសវៀងអីមួយដែរជាអំពើដែរមិនល្អអីមួយចឹងហាសអ៊ុំ?

ខ៖ អូ៎!លក្ខណះអោយបញ្ហារឿងកូនចៅយើងនឹងជៀសវៀងហោស?

កៈ  បាទអ៊ុំមួយនឹងអ៊ុំ?

ខៈ  នឹងអោយវាជៀសវៀងបើសិនជាមានកូនប្រុសវិញកុំអោយជក់គ្រឿងញៀនអីចឹង

កៈ  បាទមួយនឹងអ៊ុំ

ខៈ  នឹងហើយមិនអោយវាជាប់នៅអំពើនឹងវាមិនល្អទេនឹង

កៈ  ចុះអ៊ុំមានស្អីផ្សេងដែរចង់ផ្តែផ្តាំទៅពួកគាត់ទៀតទេអ៊ុំ?

ខៈ  ហើយខ្ញុំចង់ផ្តែផ្តាំពួកគាត់នឹងអោយចេះរៀនសូត្រអោយបានជ្រៅជ្រះនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  វាស្រួលក្នុងការប្រកបមុខរបរអីដូចថាវាមិនសូវជាប្រកំលាំងហាស

កៈ  ចឹងហោសអ៊ុំ?

ខៈ  បាទខ្ញុំមានតែប៉ុណ្ណឹងឯងនឹង

កៈ
អ៊ូ!បាទអ៊ុំចឹងជាចុងក្រោយខ្ញុំអរគុណាច្រើនអ៊ុំដែរបានផ្តល់ពេលវេលាដើម្បីអោយខ្ញុំបានសំភាសន៍ដែរ ទាក់ទងពីប្រវត្តិរបស់អ៊ុំចឹងហាស
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលា ដើម្បីតំកល់ទុកអ៊ុំចឹងបាទអរគុណាច្រើនអ៊ុំ៕៕៕